ព្រះហស្តលេខា និងចុះហត្ថលេខាតទៅ ។

នាយករដ្ឋមន្ត្រីទី ១
ព្រះហស្តលេខានិងត្រា
**នរោត្តម រណឫទ្ធិ**

នាយករដ្ឋមន្ត្រីទី ២
ហត្ថលេខានិងត្រា
**ហ៊ុន សែន**

* * *

រាជធានីភ្នំពេញ ,ថ្ងៃទី ២៥ ខែ មេសា ឆ្នាំ ១៩៩៦

**អនុក្រឹត្យលេខ ១៧ អនក្រ.បក**

**ស្តីពីការកែសំរួលប្រព័ន្ធបៀវត្សរបស់**

**កងយោធពលខេមរភូមិន្ទ**

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ របស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១-១១-៩៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា .
- បានឃើញច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី ដែលប្រកាសអោយប្រើ ដោយព្រះរាជក្រម ចុះថ្ងៃទី ២០ កក្កដា ឆ្នាំ ១៩៩៤
- បានឃើញអនុក្រឹត្យលេខ ២៣ អនក្រ. ចុះថ្ងៃទី ១០ កក្កដា ឆ្នាំ ១៩៩២ របស់ក្រុមប្រឹក្សារដ្ឋ មន្ត្រីនៃរដ្ឋកម្ពុជា ស្តីពីការកែលំអបៀវត្សរបស់កងទ័ព
- តាមសំណើរបស់ក្រសួងការពារជាតិ

**សំរេច**

**មាត្រា ១** : អនុញ្ញាតអោយប្រើប្រាស់ប្រព័ន្ធបៀវត្សមូលដ្ឋានរបស់កងយោធពលខេមរភូមិន្ទ ទៅតាមឋានន្តរសក្តិចែកចេញជា ២០ ថ្នាក់ ដូចខាងក្រោម :

| ល.រ | ឋានន្តរសក្តិ | កាំបៀវត្ស |
|---|---|---|
| ១ | នាយឧត្តមសេនីយ៍ | ៧៤.៥០០៛ |
| ២ | ឧត្តមសេនីយ៍ឯក | ៧២.៥០០៛ |
| ៣ | ឧត្តមសេនីយ៍ទោ | ៧០.៥០០៛ |
| ៤ | ឧត្តមសេនីយ៍ត្រី | ៦៨.៥០០៛ |
| ៥ | វរសេនីយ៍ឯក | ៦៤.៥០០៛ |
| ៦ | វរសេនីយ៍ទោ | ៥៨.៥០០៛ |
| ៧ | វរសេនីយ៍ត្រី | ៥៤.៥០០៛ |
| ៨ | អនុសេនីយ៍ឯក | ៤៤.៤០០៛ |
| ៩ | អនុសេនីយ៍ទោ | ៤០.៤០០៛ |
| ១០ | អនុសេនីយ៍ត្រី | ៣៦.៤០០៛ |
| ១១ | នាយចំណង់ | ៣២.៤០០៛ |
| ១២ | ព្រិន្ទបាលឯក | ២៨.៤០០៛ |
| ១៣ | ព្រិន្ទបាលទោ | ២៧.៤០០៛ |
| ១៤ | ពលបាលឯក | ២៦.៤០០៛ |
| ១៥ | ពលបាលទោ | ២៥.៤០០៛ |
| ១៦ | ពលបាលត្រី | ២៤.៥០០៛ |
| ១៧ | នាយឯក | ២៣.៤០០៛ |
| ១៨ | នាយទោ | ២៣.០០០៛ |
| ១៩ | ពលឯក | ២២.៥០០៛ |
| ២០ | ពលទោ | ២២.០០០៛ |

**មាត្រា ២ :** ប្រាក់ម្ហូបរបស់កងយោធពលខេមរភូមិន្ទ គឺជាប្រាក់បំណាច់ដោយឡែកសំរាប់ទិញម្ហូបអាហារនៅទីផ្សារអោយបានស្មើនិងកំរិតកំដៅ ២.៩៦៦កាឡូរី ។ ជាបណ្តោះអាសន្នផ្តល់ជារបបម្នាក់៩០០៛ ( ប្រាំបួនរយរៀល មួយ ថ្ងៃដោយមិនគិតថ្លៃអង្ករ ០,៧៥ គីឡូក្រាម ម្នាក់មួយថ្ងៃដែលត្រូវផ្តល់ដោយឡែក ។

– ចំពោះប្រាក់អាហាររបស់កងយោធពលជាប្រភេទទ័ពជំនាញ ក្រសួងការពារជាតិត្រូវពិចារណាកំណត់ដោយឡែក ។

**មាត្រា ៣** : ប្រាក់បំណាច់តំបន់ដាច់ស្រយាលត្រូវបើកផ្តល់ ១.៥០០៛ ម្នាក់១ខែ ចំពោះកងយោធពលខេមរភូមិន្ទ ដែលឈរជើងក្នុងភូមិសាស្ត្រត្រូវផ្តល់របប ដូចបុគ្គលិករដ្ឋដែរ ។

**មាត្រា ៤** : ប្រាក់បំណាច់មុខងាររបស់កងយោធពលខេមរភូមិន្ទ ដែលធ្វើការក្នុងក្របខ័ណ្ឌជំនាញ ត្រូវទទួលរបបដូចខាងក្រោម :

| | | |
|---|---|---|
| ១–អ្នកបើកបររថយន្តធុនធ្ងន់ | ម្នាក់ក្នុង ១ ខែ | ១.៥០០៛ |
| ២–អាកាសយានិក | ម្នាក់ក្នុង ១ ខែ | ១.៣០០៛ |
| ៣–កងទ័ពជើងទឹក | ម្នាក់ក្នុង ១ ខែ | ១.១០០៛ |
| ៤–អ្នកបើកបររថក្រោះ | ម្នាក់ក្នុង ១ ខែ | ១.០០០៛ |
| ៥–កងទ័ពជាង | ម្នាក់ក្នុង ១ ខែ | ៩០០៛ |

**មាត្រា ៥** : ចំពោះបុគ្គលិកដែលធ្វើការក្នុងក្របខ័ណ្ឌជាកម្មករក្រសួងការពារជាតិ ត្រូវផ្អែកលើសេចក្តីត្រូវការនិង សមត្ថកិច្ចជំនាញ ដើម្បីផ្តល់បៀវត្សតាមកាំ ប្រភេទដូចក្របខ័ណ្ឌកម្មកររដ្ឋក្នុងតារាងខាងក្រោម :

| ប្រភេទ. កាំ | ១ | ២ | ៣ | ៤ | ៥ | ៦ |
|---|---|---|---|---|---|---|
| គ១ | ២៦.៤០០៛ | ២៨.៦០០៛ | ៣១.៤០០៛ | ៣៤.៣០០៛ | ៣៧.១០០៛ | ៤០.០០០៛ |
| គ២ | ២៤.០០០៛ | ២៦.៤០០៛ | ២៩.៤០០៛ | ៣២.៥០០៛ | ៣៥.៥០០៛ | ៣៨.៥០០៛ |
| គ៣ | ២១.៦០០៛ | ២៣.៧០០៛ | ២៥.៩០០៛ | ២៨.២០០៛ | ៣០.៤០០៛ | ៣៣.២០០៛ |
| គ៤ | ១៥.៨០០៛ | ១៧.២០០៛ | ១៩.២០០៛ | ២១.០០០៛ | ២៣.០០០៛ | ២៥.២០០៛ |

**មាត្រា ៦** : ប្រាក់បំណាច់មានលក្ខណៈជាគ្រួសារ

– កងយោធពលម្នាក់ ត្រូវបានផ្តល់របបប្រាក់បំណាច់ឧបត្ថម្ភគ្រួសារ ៣.០០០៛ មួយខែ

– កូនកងយោធពល ត្រូវបានផ្តល់របបប្រាក់បំណាច់ឧបត្ថម្ភ ២.៥០០៛ ក្នុងកូនម្នាក់មួយខែ

**មាត្រា ៧** : ក្រសួងការពារជាតិ ត្រូវបើករបបឧបត្ថម្ភដល់កងជីវពលដូចខាងក្រោម :

១–កងជីវពលការពារ និង ប្រតិបត្តិការផ្តល់របបម្ហូបប្រចាំថ្ងៃដូចកងយោធពល និង ផ្តល់ជាប្រាក់សំរាប់ទិញអង្ករដោយខ្លួនឯង ។

២–កងជីវពលឃុំ ផ្តល់ជាប្រាក់សំរាប់ទិញអង្ករ ១៨ គីឡូក្រាម និងអំបិល ២ គីឡូក្រាម ១ខែ ។

**មាត្រា ៨** : បទបញ្ញត្តិទាំងឡាយណា ដែលមានន័យខ្ទឹមសារផ្ទុយពីអនុក្រឹត្យនេះ ត្រូវចាត់ជានិរាករណ៍ ។

**មាត្រា ៩** : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងការពារជាតិ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ និង បណ្តាក្រសួងស្ថាប័នដែលមានការពាក់ព័ន្ធ ត្រូវទទួលអនុវត្តអនុក្រឹត្យនេះអោយមានប្រសិទ្ធភាពខ្ពស់ ។

| នាយករដ្ឋមន្ត្រីទី ១ | នាយករដ្ឋមន្ត្រីទី ២ |
|---|---|
| ព្រះហស្ថលេខានិងត្រា | ហត្ថលេខានិងត្រា |
| **នរោត្តម រណឫទ្ធិ** | **ហ៊ុន សែន** |

* * *

រាជធានីភ្នំពេញ,ថ្ងៃទី ២៥ ខែ មេសា ឆ្នាំ ១៩៩៦

**អនុក្រឹត្យលេខ : ១៨ អនក្រ.បក**

**ស្តីពីការបង្កើតគណៈកម្មាធិការនីតិកម្ម**

**នៃអាជ្ញាធរជាតិទទួលបន្ទុកកិច្ចការព្រំដែន**

**រាជរដ្ឋាភិបាលកម្ពុជា**

– បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

– បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែង តាំងរាជរដ្ឋាភិបាល ។